# ថ្នាំបង្ការកុំឲ្យមានកូនជាបន្ទាន់អាសន្ន

## ព័ត៌មានស័រាប់អ្នកជំងឺ



### តើអ្វីជាថ្នាំបង្ការកុំឲ្យមានកូនជាបន្ទាន់អាសន្ន (EC)?

- ថ្នាំ EC (ហៅម៉្យាងទៀតថាថ្នាំក្រោយពេលព្រឹក) គឺជាថ្នាំការពារមិនឲ្យមានកូន ជាបន្ទាន់អាសន្ន ។
- អ្នកគួរតែប្រើវា បើសិនជាអ្នកបានសេពសន្ថវៈ ហើយ៖
  - គា្មនប្រើថ្នាំការពារមិនឲ្យមានកូនប្រភេទណាមួយ;
  - បានប្រើស្រោមអនាម័យដែលធ្លាយ; ឬ
  - ភ្លេចមិនបានលេបថ្នាំការពារមិនឲ្យមានកូន 2 ដងឬលើសក្នុងខែនេះ ។

### តើខ្ញុំអាចទទួលថ្នាំ EC នៅទីណា?

- អ្នកអាចទទួលថ្នាំ EC ពីអ្នកផ្តល់ការថែទាំសុខភាពឬ ឱសថស្ថានណាមួយ ។
- បើសិនជាអ្នកមានអាយុលើស 17 ឆ្នាំ ឬចាស់ជាងមិនចាំបាច់មានវេជ្ជបញ្ជាទេ ។
- ថ្នាំ EC គឺមានសុវត្ថិភាព និងប្រសិទ្ធិភាពទោះជាអាយុប៉ុណ្ណាក៏ដោយ ក៏ប៉ុន្តែ បើសិនជាអ្នកមានអាយុក្រោម 17 ឆ្នាំ អ្នកត្រូវតែមានសំបុត្រវេជ្ជបញ្ជា ។

### តើមានការណែនាំអ្វីខ្លះសំរាប់ការប្រើថ្នាំ EC?

- ថ្នាំ Plan B® និង Next Choice™: លេបមួយគ្រាប់ភា្លម; រួចលេប គ្រាប់ទីពីរ 12 ម៉ោងក្រោយមក ។
- ថ្នាំ Plan B® One-Step: លេបមួយគ្រាប់ភា្លម ។

### តើខ្ញុំគួរតែលេបថ្នាំ EC ពេលណា?

- ថ្នាំ EC មានប្រសិទ្ធិភាពបំផុត បើអ្នកប្រើវា **ក្នុងរវាង 3 ថ្ងៃក្រោយពីបានសេពសន្ថវៈដោយគា្មនការការពារ** ។
- ថ្នាំ EC មានប្រសិទ្ធិភាពរហូតដល់រយៈពេល **5 ថ្ងៃក្រោយពីបានសេពសន្ថវៈដោយគា្មនការការពារ ។**
- ថ្នាំ EC នឹងមិនមានប្រសិទ្ធិភាពទេ**ក្រោយពីរយៈពេល 5** ថ្ងៃ ។

### តើថ្នាំ EC មានប្រសិទ្ធិភាពរបៀបណា?

- ថ្នាំ EC មានជាតិអ័រម៉ូនដូចគ្នាដែលមានប្រើនៅក្នុងថ្នាំការពារមិនឲ្យមានកូនធម្មតា ។
- **ថ្នាំ EC គឺមិនមែនជាថ្នាំសំរាប់រំលូតកូនទេ** ។ ថ្នាំនេះគឺការពារមិនឲ្យមានគភ៌ ។ វាមិនបញ្ឈប់ ហើយ មិនមានប៉ះពាល់អ្វីដល់គភ៌ ដែលកំពុងតែមាននោះទេ ។

### តើនរណាមិនគួរប្រើថ្នាំ EC ?

- គេមិនគួរប្រើថ្នាំ EC ទេ បើសិនជា៖
  - អ្នកមានគភ៌ព្រោះថ្នាំនេះមិនមានប្រសិទ្ធិភាពទេ;
  - អ្នកមានប្រតិកម្មជាតិអ័រម៉ូននៅក្នុងថ្នាំការពារមិនឲ្យមានគភ៌ ។

### តើផលប៉ះពាល់អ្វីខ្លះដែលខ្ញុំនឹងមានពីការប្រើថ្នាំ EC?

- អ្នកប្រហែលមានការក្អួតចង្អោរ ឈឺក្រពះ ឈឺក្បាលឬវិលមុខ ។
- អ្នកប្រហែលធ្លាក់ឈាមតិចៗ (spotting) មុនពេលអ្នកមានរដូវ ឬផ្លាស់ប្តូរនៅពេលធ្លាក់រដូវលើកក្រោយ ។

### តើខ្ញុំត្រូវធ្វើយ៉ាងណា ក្រោយពីខ្ញុំលេបថ្នាំ EC?

- បន្តប្រើថ្នាំការពារមិនឲ្យមានកូនធម្មតារបស់អ្នក ឬចាប់ផ្តើមប្រើថ្នាំ ការពារមិនឲ្យមានកូន ។
- និយាយជាមួយវេជ្ជបណ្ឌិតណាម្នាក់អំពីជម្រើសនៃការប្រើថ្នាំការពារ មិនឲ្យមានកូនរបស់អ្នក ។
- បើសិនជាអ្នកមានមករដូវក្នុងរវាងពីអាទិត្យចាប់ពីពេលប្រើថ្នាំ EC អ្នកគួរតែធ្វើតេស្តអំពីការមានគភ៌ ។

**សំរាប់ព័ត៌មានបន្ថែម៖ ទូរស័ព្ទមកលេខ:**
**www.mynextchoice.com ឬ 1-866-992-8766**
**www.planbonestep.com ឬ 1-800-330-1271**

ថវិការជួយឧបត្ថម្ភសំរាប់ការបោះពុម្ព និងចែកផ្សាយឯកសារនេះបានផ្តល់ដោយថវិការជំនួយអប់រំពីអង្គការស្រាវជ្រាវ **DURAmed Research, Inc.,** ផែនការសុខភាព **Neighborhood Health Plan** នៃរដ្ឋ **RI** និង **UnitedHealthcare**

December, 2009